កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ខែសីហា ២០១២
ករណីអ្នកការពារសិទ្ធិមនុស្ស លោក ម៉ម សូណង់ដូ

សេចក្តីផ្តើម

កំណត់ត្រាសង្ខេបនេះ លើកឡើងអំពីទិដ្ឋភាពទូទៅនៃករណីរបស់លោក ម៉ម សូណង់ដូ ប្រធានស្ថានីយវិទ្យុសំបុកឃ្មុំ និងជាប្រធានសមាគមអ្នកប្រជាធិបតេយ្យ ដែលត្រូវបានប៉ូលីសមួយក្រុមប្រហែល២០នាក់ ចាប់ខ្លួនកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ នៅផ្ទះរបស់គាត់ ដោយផ្អែកលើបទចោទប្រកាន់ទាក់ទងនឹងចលនាបង្កើតតំបន់អបគមន៍ក្នុងខេត្តក្រចេះ។ បច្ចុប្បន្ននេះ គាត់កំពុងត្រូវគេឃុំឃាំងដោយមិនព្រមឲ្យមានការធានាឲ្យនៅក្រៅឃុំ ក្នុងពន្ធនាគារព្រៃស ក្រុងភ្នំពេញ ទោះបីជាគាត់សុខចិត្តវិលត្រឡប់ចូលក្នុងប្រទេសវិញសម្រាប់ការចោទសួរអំពីករណីនេះក៏ដោយ។ នេះមិនមែនជាលើកទីមួយទេ ដែលលោក ម៉ម សូណង់ដូ ត្រូវបានគេចាប់ដាក់ពន្ធនាគារក្រោមបទចោទដែលមានចរិតលក្ខណៈផ្អែកនយោបាយ ដោយសារឆន្ទៈរបស់គាត់ក្នុងការរិះគន់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) និង ជំហរដ៏រឹងមាំរបស់គាត់ក្នុងការប្រឆាំងនឹងការបណ្តេញចេញនិងការចាប់យកដីក្នុងប្រទេសកម្ពុជា បានបណ្តាលឲ្យគាត់ជាប់ក្នុងពន្ធនាគារចំនួនពីរដងរួចមកហើយ។

ការចាប់ខ្លួននិងការឃុំខ្លួនអ្នកការពារសិទ្ធិដ៏ល្បីល្បាញមួយរូបនេះ កើតឡើងក្នុងរយៈពេលត្រឹមតែមួយថ្ងៃក្រោយពេលបិទវេទិកាថ្នាក់តំបន់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) នៅក្រុងភ្នំពេញ ដែលក្នុងនោះក៏មានការចូលរួមពី រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក លោកស្រី ហ៊ីលឡារី ក្លីនតុន នាយឧត្តមស្នងការកិច្ចការបរទេសរបស់សហព័ន្ធអឺរ៉ុបលោកស្រី ខាថឺរីន អាសតុន និងតំណាងប្រទេសសមាជិកអាស៊ានជាច្រើន ហើយការចាប់ខ្លួននេះគឺជាដំណើរការថយក្រោយមួយទៀតនៃលទ្ធិប្រជាធិបតេយ្យក្នុងព្រះរាជាណាចក្រកម្ពុជា (កម្ពុជា)។

ការចាប់ខ្លួនលោក ម៉ម សូណង់ដូ ត្រូវបានជឿថាមានជាប់ពាក់ព័ន្ធទៅនឹងរបាយការណ៍មួយដែលត្រូវបានផ្សព្វផ្សាយតាមវិទ្យុសំបុកឃ្មុំ ពិភាក្សាស្តីអំពីករណីដែលប្រធានចលនាអំណាចពលរដ្ឋខ្មែរ លោក សួន សេរីរដ្ឋា បាននាំយកបទចោទប្រកាន់ស្តីពីការចូលរួមរបស់រដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅការិយាល័យព្រះរាជអាជ្ញានៃតុលាការព្រហ្ម

ទណ្ឌអន្តរ-ជាតិ។ ការចាប់ខ្លួនលោក ម៉ម សូណង់ដូ កើតឡើងមួយថ្ងៃបន្ទាប់ពីការផ្សាយនេះ ហើយទង្វើនេះគឺជាឧទាហរណ៍មួយទៀត ដែលរដ្ឋាភិបាលប្រើប្រាស់ប្រព័ន្ធតុលាការដែលរងឥទ្ធិពលនយោបាយ ដើម្បីបំភិតបំភ័យ និងបំបិទសំឡេងប្រឆាំង។

កំណត់ត្រាសង្ខេបនេះសរសេរឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ឧបទ្វេវហេតុនៅខេត្តក្រចេះ

លោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួនទាក់ទងនឹងជម្លោះដីធ្លីដ៏រ៉ាំរ៉ៃមួយ នៅក្នុងខេត្តក្រចេះ ពាក់ព័ន្ធនឹងក្រុមហ៊ុនរុស្ស៊ីមួយឈ្មោះ កាសូទីម ដែលជាអ្នកទទួលបានដីសម្បទានសេដ្ឋកិច្ចចំនួន ១៥,០០០ ហិចតា។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំនេះ កម្លាំងនគរបាល និងយោធាប្រដាប់អាវុធរាប់រយនាក់ បានចូលទៅភូមិប្រម៉ា ក្នុងគោលបំណងបណ្តេញប្រជាពលរដ្ឋប្រហែល ១០០០ គ្រួសារដែលកំពុងរស់នៅលើដីសម្បទាននោះ។ អ្នកភូមិបដិសេធមិនព្រមចេញពីដីរបស់ពួកគាត់ ហើយពេលនោះ កម្លាំងអាជ្ញាធរបានបើកការបាញ់រះ បណ្តាលឲ្យក្មេងស្រីម្នាក់ឈ្មោះ ហេង ចន្តា អាយុ១៤ឆ្នាំ ស្លាប់បាត់បង់ជីវិត។ ឧបទ្វេវហេតុនេះកើតឡើងមិនយូរប៉ុន្មានក្រោយពេលដែលលោកនាយករដ្ឋមន្ត្រីបានសន្យាបញ្ឈប់ការផ្តល់ដីសម្បទានជាបណ្តោះអាសន្ន និងពិនិត្យឡើងវិញទៅលើសម្បទានដែលកំពុងមានស្រាប់។

បន្ទាប់ពីឧបទ្វេវហេតុនេះ ក្រុមនគរបាលបានចាប់ខ្លួនមនុស្សមួយចំនួននៅតំបន់នោះ ដែលត្រូវបានចាត់ទុកថាជាអ្នកចង់បង្កើតតំបន់អបគមន៍ ទាមទារឯករាជ្យពីប្រទេសកម្ពុជា។ រដ្ឋាភិបាលបានអះអាងថាជនបង្កើតតំបន់អបគមន៍ទាំងនេះ បានចូលរួមផែនការក្បត់ជាមួយសមាគមអ្នកប្រជា-ធិបតេយ្យដឹកនាំដោយលោក ម៉ម សូណង់ដូ។ មិនទាន់មានភស្តុតាងសម្រាប់ការអះអាងនេះនៅឡើយទេ។ នៅថ្ងៃ២៦ ខែមិថុនា ឆ្នាំ២០១២ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងសុន្ទរកថានៅមជ្ឈមណ្ឌលកោះពេជ្រក្នុងក្រុងភ្នំពេញ ដែលពេលនោះគាត់បានអំពាវនាវឲ្យមានការចាប់ខ្លួន លោក ម៉ម សូណង់ដូ ដោយផ្អែកលើមូលហេតុថាលោក ម៉ម សូណង់ដូ កំពុងដឹកនាំផែនការទម្លាក់រដ្ឋាភិ-បាលកម្ពុជា និងប៉ុនប៉ងបង្កើតរដ្ឋក្នុងរដ្ឋ។

បទចោទលើរូបលោក ម៉ម សូណង់ដូ (ដូចមានរៀបរាប់លម្អិតខាងក្រោម) ហាក់ដូចជាចេតនាក្នុងការបង្កើតដំណើររឿងមួយជំនួសឲ្យព្រឹត្តិការណ៍ដែលបានកើតឡើង ក្នុងខេត្តក្រចេះ នៅថ្ងៃទី១៦ ខែឧសភា និងបង្វែរការចាប់អារម្មណ៍ពីការខកខានរបស់រដ្ឋាភិបាលដែលមិនបានរៀបចំឲ្យមានការស៊ើបអង្កេតសមរម្យមួយទៅលើការស្លាប់របស់កុមារី ហេង ចន្តា នោះឡើយ។ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២ សមាគមអ្នកប្រជាធិបតេយ្យ បានរៀបចំសន្និសីទសារព័ត៌មាន

មួយ ហើយបានបដិសេធថាមិនមានការពាក់ព័ន្ធណាមួយរវាងលោក ម៉ម សូណង់ដូ និងលោក ប៊ុន រដ្ឋា បុគ្គលដែលអាជ្ញាធរកំណត់មុខសញ្ញាថាជាមេដឹកនាំផែនការបង្កើតតំបន់អបគមន៍នោះទេ។ នៅក្នុងសន្និសីទសារព័ត៌មាននេះ សមាគមអ្នកប្រជាធិបតេយ្យ បានបញ្ជាក់ថា លោក ប៊ុន រដ្ឋា មិនមែនជាសមាជិកសកម្មរបស់សមាគមនេះទេ ហើយលោករដ្ឋាខ្លួនឯង ក៏បានបដិសេធថាមិនមានការជាប់ពាក់ព័ន្ធណាមួយរបស់លោក ម៉ម សូណង់ដូ នៅក្នុងឧបទ្វេរហេតុក្នុងខេត្តក្រចេះនោះដែរ។

បទចោទប្រកាន់លើលោក ម៉ម សូណង់ដូ

លោក ម៉ម សូណង់ដូ ត្រូវរងការចោទប្រកាន់នៅថ្ងៃ១៦ ខែកក្កដា ឆ្នាំ២០១២ ក្រោមមាត្រា ៤៥៦, ៤៥៧, ៤៦៤, ៥០៤ និង ៦០៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា[1] ដែលគាត់អាចប្រឈមនឹងការកាត់ឲ្យជាប់ទោសសរុបរហូតដល់ទៅ៣០ឆ្នាំ ប្រសិនបើគេរកឃើញថាគាត់ពិតជាមានកំហុសមែន។ បទចោទប្រកាន់ និងកម្រិតទោសដែលលោក ម៉ម សូណង់ដូ ប្រឈម មានដូចខាងក្រោម៖

- បទចូលរួមក្នុងចលនាបះបោរ ដែលអាចប្រឈមនឹងការផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ (មាត្រា ៤៥៦ និង ៤៥៧)
- បទញុះញង់ឲ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងអាជ្ញាធរស្របច្បាប់ ដែលអាចប្រឈមនឹងការផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ ទៅ ៣០ ឆ្នាំ (មាត្រា ៤៦៤)[2]
- បទប្រឆាំងនឹងអ្នករាជការសាធារណៈ ដែលអាចប្រឈមនឹងការផ្តន្ទាទោសដាក់ពន្ធនា-គារពី ៦ខែ ទៅ ១ ឆ្នាំ និងការពិន័យ (មាត្រា ៥០៤)
- បទជ្រៀតជ្រែកដោយខុសច្បាប់ទៅក្នុងការបំពេញមុខងារសាធារណៈ ដែលអាចប្រឈមនឹងការផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ទៅ ៣ ឆ្នាំ និងការពិន័យ (មាត្រា ៦០៩)

ការរំលោភសិទ្ធិមនុស្ស

ការចាប់ខ្លួន និងការឃុំខ្លួនលោក ម៉ម សូណង់ដូ ជាការរំលោភទាំងច្បាប់ជាតិ និងច្បាប់អន្តរ-ជាតិ។ ករណីនេះបង្ហាញយ៉ាងច្បាស់អំពីកង្វះការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ពីសំណាក់រដ្ឋាភិបាលកម្ពុជា លំហសម្រាប់ការបញ្ចេញមតិដោយសេរីកាន់តែរួញខ្ចីចទៅៗ និងអំពីការប្រើប្រាស់ប្រព័ន្ធតុលាការដោយខុសឆ្គងក្នុងការបំបិទសំឡេងអ្នកប្រឆាំង។

---

[1] សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH), ថ្ងៃ១៧ កក្កដា ២០១២, "ប្រទេសកម្ពុជា៖ នាយកស្ថានីយ៍វិទ្យុឯករាជ្យលោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួននិងរងការចោទប្រកាន់" http://www.fidh.org/CAMBODIA-Independent-radio-station ថ្ងៃទី ២០ កក្កដា ២០១២] ។

[2] មាត្រា២៨ នៃក្រមព្រហ្មទណ្ឌ បានកំណត់អំពីអ្វីជាអ្នកញុះញង់នៃបទឧក្រិដ្ឋឬបទមជ្ឈឹម។ ការញុះញង់បទឧក្រិដ្ឋអាចទទួលទណ្ឌកម្មច្រើនជាង៥ឆ្នាំតែតិចជាង៣០ឆ្នាំ បន្ថែមលើការពិន័យ។ អ្នកញុះញង់បទមជ្ឈឹមអាចទទួលទណ្ឌកម្មដោយការជាប់ពន្ធនាគារពី៦ថ្ងៃដល់៥ឆ្នាំ និងការពិន័យ

សេរីភាពក្នុងការបញ្ចេញមតិ ត្រូវបានធានាចំពោះពលរដ្ឋកម្ពុជាគ្រប់រូបក្រោមមាត្រា៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) និង មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅខែឧសភាឆ្នាំ១៩៩២។ ការចោទប្រកាន់ដោយគ្មានភស្តុតាងទៅលើរូបលោក ម៉ម សូណង់ដូ និងការចាប់ខ្លួនបន្ទាប់ពីការចោទប្រកាន់នោះ មិនត្រឹមតែជាការបដិសេធទាំងស្រុង នូវសេរីភាពក្នុងការសម្តែងមតិរបស់គាត់ប៉ុណ្ណោះទេ តែថែមទាំងអាចជាការបដិសេធ នូវការបញ្ចេញមតិដោយសេរីរបស់អ្នកដែលប្រើប្រាស់ស្ថានីយវិទ្យុក្នុងការផ្សព្វផ្សាយព័ត៌មាន និងមតិឯករាជ្យ ព្រមទាំងសិទ្ធិសេរីភាពទទួលបានព័ត៌មានរបស់អ្នកស្តាប់ផងដែរ[3]។ តាមសម្តីរបស់ភរិយាលោក ម៉ម សូណង់ដូ ក្រោយការចាប់ខ្លួនស្វាមីរបស់គាត់ ស្ថានីយវិទ្យុនេះក៏បានជួបប្រទះនឹងវិបត្តិហិរញ្ញវត្ថុ។ តាមពិតទៅ ការឃុំខ្លួនលោក ម៉ម សូណង់ដូ មួយផ្នែក ជាប់ទាក់ទងនឹងឆន្ទៈរបស់គាត់ក្នុងការផ្តល់វេទិកាសម្រាប់បុគ្គលផ្សេងទៀត ដើម្បីបញ្ចេញទស្សនៈដោយសេរីប្រឆាំងនឹងរដ្ឋាភិបាលផងដែរ[4]។ ការសន្និដ្ឋាននេះជាក្តីបារម្ភដោយឡែកមួយ ដោយហេតុថា វិទ្យុសំបុកឃ្មុំ ដូចបានរៀបរាប់ខាងលើ ជាវិទ្យុមួយក្នុងចំណោមវិទ្យុឯករាជ្យតែបីគត់កំពុងប្រតិបត្តិការនៅកម្ពុជា។

កាលៈទេសៈនៃការចាប់ខ្លួនលោក ម៉ម សូណង់ដូ បានធ្វើឲ្យកើនឡើងនូវក្តីបារម្ភជាចាំបាច់ស្តីអំពីឯករាជ្យភាពរបស់តុលាការកម្ពុជា។ មាត្រា១០៩ និង១១១ នៃរដ្ឋធម្មនុញ្ញ បានលើកឡើងថា ប្រព័ន្ធតុលាការនៅកម្ពុជាត្រូវតែឯករាជ្យ និងដាច់ចេញពីប្រព័ន្ធនីតិប្រតិបត្តិ។ នៅក្នុងសុន្ទរកថាជាសាធារណៈមួយកាលពីថ្ងៃ២៦ ខែមិថុនា ឆ្នាំ២០១២ និងបានផ្សាយនៅតាមទូរទស្សន៍ លោកនាយករដ្ឋមន្ត្រីផ្ទាល់ បានអំពាវនាវឲ្យមានការចាប់ខ្លួនលោក ម៉ម សូណង់ដូ ពីបទញុះញង់ឲ្យមានចលនាបង្កើតអបគមន៍ក្នុងខេត្តក្រចេះ។ មកដល់ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១២ ចៅក្រមស៊ើបអង្កេត ចុក ងួន នៅតុលាការខេត្តក្រចេះ បានចេញដីកាចាប់ខ្លួនមួយដោយបានចោទលោក ម៉ម សូណង់ដូ ពីបទឧក្រិដ្ឋកម្មទាក់ទងនឹងការចូលរួមក្នុង "ចលនាបះបោរ[5]"។ កិច្ចការនេះ បានបង្ហាញថា កាតព្វកិច្ចនៃការបែងចែកអំណាចរវាងអង្គនីតិប្រតិបត្តិ និងតុលាការដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងក៏ដូចជាមានចែងក្នុងច្បាប់អន្តរជាតិ មិនត្រូវបានប្រទេសកម្ពុជាគោរពតាមនោះទេ។

លើសពីនេះទៀត នៅទីណាដែលតុលាការត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាល ដែលប្រមុខរដ្ឋាភិបាលនោះបានបង្ហាញអំពីជំនឿរបស់ខ្លួនថាលោក ម៉ម សូណង់ដូ មានកំហុស និង

[3] សិទ្ធិទទួលបានសេរីភាពព័ត៌មាន ឬ "សិទ្ធិក្នុងការដឹង" ក៏មានការពារក្រោមមាត្រា១៩ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែរ

[4] សូមមើលខាងលើ

[5] សេចក្តីថ្លែងការណ៍រួមរបស់អង្គការលីកាដូ ថ្ងៃ១៦ កក្កដា ២០១២ "ដោះលែងលោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយឯករាជ្យចំណាស់បំផុតក្នុងប្រទេសកម្ពុជា"

អំពារនាវឲ្យមានការចាប់ខ្លួនគាត់ហើយនោះ នឹងមានការចោទជាសំណួរ ថាតើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ពីតុលាការឯករាជ្យ និងមិនលម្អៀងដូចមានចែងក្នុងមាត្រា១៤នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះ នឹងត្រូវបានគោរពដែរឬទេ។ មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏បានបញ្ជាក់ដែរថា បុគ្គលគ្រប់រូបដែលត្រូវចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិទទួលបានការសន្មត់ជាមុនថាគ្មានទោសរហូតទាល់តែមានការរកឃើញថាមានទោសតាមច្បាប់។ ផលប្រយោជន៍នៃរិមតិសង្ស័យក៏មានចែងដោយស្មើភាពគ្នាក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញថា៖ "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។ ការប្រកាសជាសាធារណៈរបស់លោក ហ៊ុន សែន អំពីទោសកំហុសរបស់លោក ម៉ម សូណង់ដូ បញ្ជាក់ថា សិទ្ធិបែបនេះនឹងមិនត្រូវបានផ្តល់ជូនលោក ម៉ម សូណង់ដូ នោះទេ។ លើសពីនេះទៅទៀត មេធាវីរបស់លោក ម៉ម សូណង់ដូ គឺលោក សុក សំអឿន ដែលជានាយកប្រតិបត្តិ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានអះអាងថា ការស្នើសុំដោះលែងកូនក្តីរបស់លោកឲ្យនៅក្រៅឃុំ ត្រូវបានបដិសេធជាច្រើនដងមកហើយ។

ទិឡុសំបុកឃ្មុំ និង លោក ម៉ម សូណង់ដូ

ឧបទ្វេរហេតុនៅខេត្តក្រចេះ គឺជាឧបទ្វេរហេតុថ្មីបំផុតនៅក្នុងយុទ្ធនាការដ៏យូរអង្វែងមួយក្នុងការបំភិតបំភ័យលោក ម៉ម សូណង់ដូ និងវិទ្យុសំបុកឃ្មុំ។ វិទ្យុសំបុកឃ្មុំត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ និងជាស្ថានីយមួយក្នុងចំណោមស្ថានីយវិទ្យុឯករាជ្យនៅកម្ពុជា។ វិទ្យុសំបុកឃ្មុំ គឺជាប្រភពព័ត៌មានមិនលម្អៀងដ៏សំខាន់មួយក្នុងប្រទេស ដែលប្រព័ន្ធផ្សព្វផ្សាយត្រូវបានត្រួតត្រាដោយគណៈ-បក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច។ ការសិក្សាថ្មីមួយរបស់ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បានបញ្ជាក់យ៉ាងច្បាស់ថា វិទ្យុ គឺជាមធ្យោបាយដែលប្រជាពលរដ្ឋកម្ពុជាទូទៅ ពេញចិត្តបំផុតក្នុងការទទួលបានព័ត៌មាន[6] ប៉ុន្តែ មានប្រភពព័ត៌មានតែបីប៉ុណ្ណោះដែលគេជឿថាមិនលម្អៀង និងមិនប្រកាន់បក្ស គឺ វិទ្យុសារិកា ដែលគ្រប់គ្រងដោយ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វ-ផ្សាយឯករាជ្យ វិទ្យុអែហ្វអឹម ១០២ របស់មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា និងវិទ្យុសំបុកឃ្មុំ[7]។ អស់រយៈពេលជាង១០ឆ្នាំមកនេះ វិទ្យុសំបុកឃ្មុំបានលក់ម៉ោងផ្សាយឲ្យទៅកម្មវិធីផ្សាយដែលបានទទួលការគាំទ្រមូលនិធិពីរដ្ឋាភិបាលសហរដ្ឋអាមេរិក រួមមាន វិទ្យុអាស៊ីសេរី និងវិទ្យុសំឡេងសហរដ្ឋអាមេរិក (វីអូអេ) ដើម្បីផ្សាយព័ត៌មាន និងបទអត្ថាធិប្បាយជាភាសាខ្មែរ។ យោងតាមភរិយារបស់លោក ម៉ម សូណង់ដូ ឈ្មោះ ឌី ជាន់តារា វិទ្យុ

[6] មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ខែមេសា ឆ្នាំ២០១២ "សេរីភាពទទួលព័ត៌មានរបស់បណ្តាញសារព័ត៌មាន ៖ ការស្រាវជ្រាវបែបជឿនលឿន និងសកម្មភាព" http://www.ccimcambodia.org/report/FOI_survey_(30_April_2012).pdf, [ចូលអានកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២]– ៥៩.៧% នៃប្រជាពលរដ្ឋដែលចូលរួមការស្ទង់មតិចូលចិត្តវិទ្យុជាងទម្រង់ដទៃទៀត។

[7] ម.ស.ម.ក ខែកក្កដា ឆ្នាំ២០១២ "ប្រព័ន្ធព័ត៌មានបែបទំនើប និងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា"

សំបុកឃ្មុំ ត្រូវបានបង្កើតឡើងដោយមានគោលបំណងផ្តល់នូវព័ត៌មានពិត ត្រឹមត្រូវ ស្តីពីភាពក្រីក្រ និងឱកាសការងារ។

ក្នុងឆ្នាំ២០០៣ លោក ម៉ម សូណង់ដូ បានជាប់ពន្ធនាគារចំនួនពីរសប្តាហ៍ បន្ទាប់ពីបានផ្សាយការនិយាយតាមទូរស័ព្ទដែលគេបានទូរស័ព្ទចូលទៅក្នុងវិទ្យុសំបុកឃ្មុំ ហើយការផ្សាយនោះត្រូវរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងនាំឲ្យមានការរើសអើង និង "ជាការផ្តល់ព័ត៌មានមិនពិតដល់សាធារណជន[8]" ក្រោមបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (ច្បាប់អ៊ុនតាក់)[9]។ បទចោទនោះជាការឆ្លើយតបនឹងការចោទប្រកាន់ដោយគ្មានភស្តុតាងដែលថា វិទ្យុសំបុកឃ្មុំបានញុះញង់ឲ្យមានកុបកម្មប្រឆាំងប្រទេសថៃ ដែលបានកើតឡើងនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣។ លោក ម៉ម សូណង់ដូ ត្រូវគេចាប់ដាក់ពន្ធនាគារម្តងទៀតដែលមានរយៈពេលបីខែ ក្នុងឆ្នាំ២០០៥ ពីបទបរិហាកេរ្តិ៍និងញុះញង់ ក្រោមច្បាប់អ៊ុនតាក់ ក្រោយពីចាក់ផ្សាយការសម្ភាសន៍របស់គាត់ជាមួយ លោក ស៊ាន ប៉ែងសៃ ជាអ្នកជំនាញធ្វើការនៅប្រទេសបារាំង ទាក់ទងនឹងសន្ធិសញ្ញាបោះបង្គោលព្រំដែនទ្វេភាគីមួយដែលរដ្ឋាភិបាលគ្រោងនឹងធ្វើឡើងជាមួយប្រទេសវៀតណាម។ កិច្ចសម្ភាសន៍នេះបានរិះគន់ថាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពាក់ព័ន្ធនឹងការផ្តល់ដីឲ្យប្រទេសវៀតណាម ក្នុងសន្ធិសញ្ញាព្រំដែនប្រទាញប្រទង់មួយដែលបានចុះហត្ថលេខានៅក្នុងឆ្នាំនោះ[10]។

លោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួនភ្លាមៗ បន្ទាប់ពីពីដំណើរត្រលប់របស់លោកមកពីអឺរ៉ុបវិញ ហើយនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២ នៅការិយាល័យអគ្គរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិក្រុងឡាអេ គាត់បានសម្ភាសលោក សួន សេរីរដ្ឋា ប្រធានចលនាអំណាចពលរដ្ឋខ្មែរ ដែលតស៊ូមតិពីបរទេស ទាមទារឲ្យមានការកែទម្រង់ប្រជាធិបតេយ្យនៅកម្ពុជា។ លោក សេរីរដ្ឋា បានដាក់សេចក្តីសម្រេចមួយទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយបានចោទប្រកាន់រដ្ឋាភិបាលកម្ពុជាពីបទចូលរួមក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធនឹងការរំលោភសិទ្ធិដីធ្លី មាន

---

[8] អែហ្វអាយឌីអេជ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ "កម្ពុជា ៖ ប្រធានស្ថានីយវិទ្យុឯករាជ្យ លោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់" http://www.fidh.org/CAMBODIA-Independent-radio-station [ចូលអានថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២]

[9] ច្បាប់អ៊ុនតាក់ ឆ្នាំ១៩៩២ - ១៩៩៣ ដែលត្រូវបានបង្កើតឡើងដើម្បីធានាថាមានការអនុវត្តន៍នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលបានចុះហត្ថលេខាក្នុងខែតុលា ឆ្នាំ១៩៩១។ អង្គការសហប្រជាជាតិ ត្រូវបានផ្តល់អំណាចដែលមិនធ្លាប់មានពីមុនក្នុងរដ្ឋអធិបតេយ្យ និងត្រូវទទួលខុសត្រូវ ក្នុងចំណោមរឿងរ៉ាវផ្សេងទៀត គឺត្រូវរៀបចំឲ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ស្ថានីតិសម្បទាចំពោះរចនាសម្ព័ន្ធប្រទេសកម្ពុជាបន្ទាប់ពីមានសង្គ្រាមស៊ីវិលរាប់សិបឆ្នាំមក និងដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ សម្រាប់ព័ត៌មានបន្ថែម សូមអាន http://www.un.org/en/peacekeeping/missions/past/untac.htm ។ មាត្រាយោងខាងលើគឺ ៥៩ ៦១ និង៦២ ។

[10] គណៈកម្មាធិការដើម្បីការពារអ្នកកាសែត ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ "គ.ក.អ ថ្កោលទោសចំពោះការឃុំខ្លួនរបស់អ្នកសារព័ត៌មានលើវិទ្យុក្នុងលិខិតផ្ញើទៅលោក ហ៊ុន សែន" http://cpj.org/2005/11/cpj-condemns-detention-of-radio-journalist-in-lett.php#more [ចូលអាននៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២] ។

ការទទួលស្គាល់តាមរយៈលិខិតទទួលឯកសាររបស់ការិយាល័យអគ្គរាជអាជ្ញាហា នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២។ កិច្ចសម្ភាសន៍ រួមជាមួយនឹងរបាយការណ៍ពេញ រាយការណ៍ដោយលោក ម៉ម សូណង់ដូ ស្តីពីការដាក់ពាក្យបណ្តឹងនោះ ត្រូវបានផ្សាយតាមវិទ្យុសំបុកឃ្មុំនៅថ្ងៃទី២៥ មិថុនា ២០១២។ នៅថ្ងៃបន្ទាប់ នាយករដ្ឋមន្ត្រីបានថ្លែងសុន្ទរកថាមួយដែលគាត់បានអំពាវនាវឲ្យមានការចាប់ខ្លួនលោក ម៉ម សូណង់ដូ។

សមាគមអ្នកប្រជាធិបតេយ្យ

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០ លោក ម៉ម សូណង់ដូ បានបង្កើតជាផ្លូវការនូវអង្គការតស៊ូមតិថ្មីមួយ ឈ្មោះ "សមាគមអ្នកប្រជាធិបតេយ្យ" មានមូលដ្ឋានក្នុងទីក្រុងភ្នំពេញ។ សមាគមនេះមានគោលបំណងដើម្បីជួយប្រទេសកម្ពុជាឲ្យក្លាយទៅជាប្រទេសគោរពនីតិរដ្ឋ លើកកម្ពស់សិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងអប់រំប្រជាជនកម្ពុជាជាពិសេសយុវជន អំពីប្រវត្តិសាស្ត្រ វប្បធម៌ និងអារ្យធម៌។ សរុបមក សមាគមនេះមានបំណងជួយដល់ប្រទេសកម្ពុជាឲ្យផ្លាស់ប្តូរទៅជាប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យពេញលេញ តាមរយៈការអប់រំ និងការផ្តល់ព័ត៌មាន និងរួមចំណែកក្នុងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ គោលបំណងទាំងនេះ និងអ្វីដែលហៅថាជាចលនាបង្កើតតំបន់អបគមន៍នៅខេត្តក្រចេះនោះ មិនមានអ្វីទាក់ទងនឹងគ្នាឡើយ។ តាមពិតទៅ នៅថ្ងៃ១៧ ខែកក្កដា ឆ្នាំ២០១២ លោក ប៊ុន រដ្ឋា ដែលត្រូវបានចោទថាជាអ្នកដឹកនាំចលនានោះ បានបញ្ជាក់នៅក្នុងបទសម្ភាសន៍មួយជាមួយវីអូអេ ថា លោក ម៉ម សូណង់ដូ មិនមានការពាក់ព័ន្ធក្នុងជម្លោះដីធ្លីក្នុងខេត្តក្រចេះនេះទាល់តែសោះ។ លើសពីនេះ លោក ប៊ុន រដ្ឋា ក៏មិនមានតំណែងអ្វីក្នុងសមាគមអ្នកប្រជាធិបតេយ្យដែរ។ ហេតុដូច្នេះ ដោយគ្មានភស្តុតាងថាលោក ម៉ម សូណង់ដូ បានផ្តល់មតិញុះញង់ប្រជាជនឲ្យបង្កើតតំបន់អបគមន៍ក្នុងប្រទេសកម្ពុជា និងដោយហេតុថាលោក ប៊ុន រដ្ឋា បានប្រតិកម្មទៅលើយោបល់ដែលចោទថាមានការ ដឹកនាំចលនាបះបោរនោះ ការចោទប្រកាន់ទៅលើលោក ម៉ម សូណង់ដូ មិនមែនជាការពិតឡើយ។ ដូចលោក ប្រ៊ែត អាដាម នាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សអាស៊ី បានមានប្រសាសន៍ថា៖ "ដំណើររឿងនេះនឹងមានភាពគួរឲ្យអស់សំណើចណាស់ ប្រសិនបើលទ្ធផលមិនអាក្រក់ពេកទេនោះ"[11]។

បរិបទនយោបាយនៅពីក្រោយការចាប់ខ្លួនលោក ម៉ម សូណង់ដូ

ការចាប់ខ្លួនលោក ម៉ម សូណង់ដូ កើតឡើងនៅពេលមានចលាចលយ៉ាងខ្លាំងក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០១២ យើងសង្កេតឃើញមានប្រជាពលរដ្ឋកម្ពុជាជាច្រើន ប្រើប្រាស់ផ្លូវ

[11] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ "កម្ពុជា ៖ បន្ទាប់ពី អាមេរិក អាស៊ាន ចាកចេញទៅ អ្នករិះគន់លើបណ្តាញសារព័ត៌មានត្រូវបានចាប់ដាក់ពន្ធនាគារ" http://www.hrw.org/news/2012/07/17/cambodia-after-us-asean-leave-media-critic-jailed [ចូលអានថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២]

ថ្នល់សម្រាប់ការតវ៉ាប្រឆាំងនឹងទង្វើអយុត្តិធម៌ ទាក់ទងនឹងសិទ្ធិដីធ្លី និងសិទ្ធិការងារ និងបញ្ហាដទៃផ្សេងទៀត។ ការធ្វើបាតុកម្មជាច្រើនត្រូវរងការចោទប្រកាន់កាន់តែច្រើនឡើង ហើយការប្រើប្រាស់ហិង្សា ជូនកាលរហូតដល់មានការបាត់បង់ជីវិត របស់កងកម្លាំងនគរបាល និងកម្លាំងយោធា បានក្លាយជារឿងធម្មតាទៅហើយ[12]។ ការបង្ក្រាបទាំងស្រុងទៅលើការបញ្ចេញមតិដោយសេរីនេះ បញ្ជាក់ថារដ្ឋាភិបាលខ្លាចចំពោះការប្រឆាំង។

ការសង្ស័យទាំងនេះ ទទួលការគាំទ្រដោយការរាយការណ៍ថ្មីៗដែលថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលគ្រប់គ្រងដោយរដ្ឋាភិបាល នឹងរារាំងមិនឲ្យលោក សម រង្ស៊ី ប្រធានបក្សប្រឆាំងដែលទើបនឹងរួមបញ្ចូលគ្នា មានឈ្មោះថា ចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ ក្នុងពេលថ្មីៗនេះ មិនឲ្យចូលរួមក្នុងយុទ្ធនាការបោះឆ្នោតជ្រើសរើសសមាជិកសភាជាតិឆ្នាំក្រោយនេះទេ[13]។ ពេលនេះ លោក សម រង្ស៊ី កំពុងនិរទេសខ្លួនក្នុងប្រទេសបារាំង ដោយរងការចោទប្រកាន់ដ៏ប្រទាញប្រទង់មួយ ក្នុងបទញុះញង់ឲ្យមានការប្រកាន់ជាតិសាសន៍ និងបំផ្លាញទ្រព្យសម្បត្តិសាធារណៈ បន្ទាប់ពីរូបលោក និងអ្នកភូមិមកពីខេត្តស្វាយរៀង បានដកបង្គោលព្រំដែនបណ្តោះអាសន្នចំនួន ៦ដើម ដែលគេអះអាងថាតំណាងឲ្យការឈ្លានពានរបស់វៀតណាមចូលក្នុងទឹកដីកម្ពុជា នៅក្នុងឆ្នាំ២០០៩[14]។ ការជំនុំជម្រះក្តីក្នុងករណី លោក សម រង្ស៊ី មិនបានគោរពតាមស្តង់ដារអន្តរជាតិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌បន្តិចណានោះទេ ដោយសារតុលាការបានហាមឃាត់មិនឲ្យសាធារណជន អ្នកសារព័ត៌មាន និងអង្គការសិទ្ធិមនុស្សចូលរួមនោះទេ។ លោកត្រូវបានផ្តន្ទាទោសកំបាំងមុខ។ ហើយលោកក៏ត្រូវបានបដិសេធមិនឲ្យមានសិទ្ធិត្រួតពិនិត្យមើលភស្តុតាងប្រឆាំងនឹងរូបលោកដែរ[15]។ គាត់ត្រូវបានគេផ្តន្ទាទោសដាក់ពន្ធនាគារចំនួនពីរឆ្នាំ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ហើយការផ្តន្ទានេះត្រូវបានតម្កល់ដោយតុលាការឧទ្ធរណ៍ក្នុងខែតុលា ឆ្នាំ២០១០។ គាត់ក៏បានប្រឈមនឹងបទចោទប្រកាន់ពី ការផ្តល់ព័ត៌មានមិនពិត និងការក្លែងបន្លំឯកសារសាធារណៈ បន្ទាប់ពីការផ្សព្វផ្សាយផែនទីមួយនៅលើគេហទំព័រគណបក្សរបស់លោក ដើម្បីបង្ហាញអំពីការឈ្លានពានទឹកដី។ លោកត្រូវបានរកឃើញថានមានទោសកំហុសពីបទចោទទាំងនេះ និងត្រូវបានផ្តន្ទាទោសកំបាំងមុខ ឲ្យជាប់ពន្ធនាគារចំនួន១០ឆ្នាំ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០។ ជាការឆ្លើយតបនឹងការ

---

[12] "យុត្តិធម៌ដែលបរាជ័យ ការប្រឆាំងតវ៉ា និងអំពើហិង្សា" http://www.atimes.com/atimes/Southeast_Asia/ND05Ae01.html ។

[13] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ "កម្ពុជា ៖ បន្ទាប់ពី អាមេរិក អាស៊ាន ចាកចេញទៅ អ្នករិះគន់លើបណ្តាញសារព័ត៌មានត្រូវបានចាប់ដាក់ពន្ធនាគារ" http://www.hrw.org/news/2012/07/17/cambodia-after-us-asean-leave-media-critic-jailed [ចូលអានថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២]

[14] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១២ "កម្ពុជា ៖ សវនាការរបស់ប្រធានគណបក្សប្រឆាំង លោក សម រង្ស៊ី គឺជារឿងគួរឲ្យអស់សំណើច" http://www.unhcr.org/refworld/docid/4b6abe8dc.html [ចូលអានថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២]

[15] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១២ "កម្ពុជា ៖ សវនាការរបស់ប្រធានគណបក្សប្រឆាំង លោក សម រង្ស៊ី គឺជារឿងគួរឲ្យអស់សំណើច" http://www.unhcr.org/refworld/docid/4b6abe8dc.html [ចូលអានថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២]

អំពារនាវពីគណបក្សប្រឆាំងនាពេលថ្មីៗនេះ ដើម្បីអនុញ្ញាតឲ្យលោក សម រង្ស៊ី វិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញឲ្យទាន់ពេលការបោះឆ្នោតនៅឆ្នាំក្រោយនោះ អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៅទីស្តីការគណៈរដ្ឋមន្ត្រី បានបំផ្លាញសេចក្តីសង្ឃឹមនោះភ្លាមៗ ដោយនិយាយថា មេដឹកនាំគណបក្សប្រឆាំង នឹងមិនត្រូវអនុញ្ញាតឲ្យវិលត្រឡប់មកវិញនោះទេ ហើយបញ្ជាក់ថា "ក្នុងសតវត្សរ៍នេះ នឹងគ្មានការសម្របសម្រួលបែបនោះទេ"[16]។

សេចក្តីសន្និដ្ឋាន

ការចោទប្រកាន់ទៅលើលោក ម៉ម សូណង់ដូ មិនមានភស្តុតាងគាំទ្រនោះទេ។ ភស្តុតាងដែលមានទាំងអស់បង្ហាញថា គាត់មិនមានការចូលរួមណាមួយក្នុងសកម្មភាពបដិវត្តន៍ និងការបង្កើតតំបន់អបគមន៍នោះទេ។ ការចូលរួមរបស់គាត់ក្នុងខេត្តក្រចេះមានតែមួយគត់ គឺការរាយការណ៍អំពីការបណ្តេញចេញដោយហិង្សា តាមរយៈវិទ្យុសំបុកឃ្មុំ។ លោក ប៊ុន រដ្ឋា ដែលជាអ្នកតំណាងសហគមន៍ក្នុងតំបន់រងជម្លោះនោះ បានបញ្ជាក់ជាសាធារណៈហើយថា ការតវ៉ា ក្នុងខេត្តក្រចេះមិនមានពាក់ព័ន្ធជាមួយនឹងសមាគមអ្នកប្រជាធិបតេយ្យ ឬ លោក ម៉ម សូណង់ដូ នោះទេ។ លើសពីនេះទៅទៀត ក៏គ្មានភស្តុតាងណាមួយ អាចបញ្ជាក់ថាលោក ប៊ុន រដ្ឋា ដឹកនាំផែនការបង្កើតតំបន់អបគមន៍នោះដែរ។ រដ្ឋាភិបាលកម្ពុជាបានប្រកាសនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១២ ថា អ្នកភូមិសរុប៦នាក់ បានសារភាពអំពីការបង្កើតតំបន់អបគមន៍ក្នុងខេត្តក្រចេះ ប៉ុន្តែ ដូចដែលជនត្រូវចោទម្នាក់ឈ្មោះ សុខ តុង បាននិយាយថា ប្រជាពលរដ្ឋត្រូវបានគេគាបសង្កត់ឲ្យសារភាពដើម្បីបានចៀសផុតពីការចាប់ខ្លួន ហើយរដ្ឋាភិបាលខកខានមិនបានស្វែងរកភស្តុតាងណាមួយដែលគួរឲ្យជឿជាក់បានសម្រាប់គាំទ្រដល់ការចោទប្រកាន់នេះឡើយ៖ "លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវតែបង្ហាញភស្តុតាងដែលចោទពួកយើងពីបទបង្កើតតំបន់ស្វយ័ត ហើយតើតំបន់ស្វយ័តនេះជាអ្វីទៅ? ... តើឲ្យខ្ញុំសារភាពកំហុសយ៉ាងម៉េច បើខ្ញុំមិនបានធ្វើខុសដូចដែលគេចោទនោះផង[17]"? លើសពីនេះទៅទៀត កងនគរបាលកម្ពុជាបានចាប់ផ្តើមបង្ក្រាបអ្នកគាំទ្រលោក ម៉ម សូណង់ដូ ដោយរារាំងពួកគេមិនឲ្យប្រមូលស្នាមមេដៃសម្រាប់ធ្វើញត្តិអំពារនាវឲ្យមានការដោះលែងគាត់នោះទេ។ អាជ្ញាធរក្នុងខេត្តយ៉ាងហោចណាស់បួន រួមមានខេត្តក្រចេះ កណ្តាល ព្រៃវែង និង តាកែវ បានហាមឃាត់សមាជិកសមាគមអ្នកប្រជាធិបតេយ្យមិនឲ្យប្រមូលស្មានមេដៃដោយលើកហេតុផលថា "ជាការរំខានសណ្តាប់ធ្នាប់សាធារណៈ"។

ការបំបិទសំឡេងប្រឆាំងដោយរដ្ឋាភិបាលកម្ពុជាមិនមែនជារឿងថ្មីនោះទេ។ ការគំរាមកំហែងនិងការវាយប្រហារបែបគាបសង្កត់ទៅលើអ្នកដែលហ៊ាននិយាយ បានក្លាយទៅជា

---

[16] "លោក សម រង្ស៊ី នឹងមិនអនុញ្ញាតឲ្យត្រលប់មកវិញនោះទេ" *សារព័ត៌មាន ឌឹ ខេមបូឌា ដេលី ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២* ទំព័រទី ១៦

[17] "មានការសារភាពច្រើនទៀតចំពោះករណី 'អបគមន៍'" , *សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍* ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២

លក្ខណៈសាមញ្ញមួយក្នុងរដ្ឋាភិបាលរបស់លោក ហ៊ុន សែន ទៅហើយ។ នៅក្នុងបរិយាកាសនៃការចាប់យកដីនិងបណ្តេញចេញដោយបង្ខំដែលកើតឡើងស្ទើរគ្រប់ទីកន្លែង ដែលថ្មីៗនេះនាំឲ្យមានការផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មានអន្តរជាតិកាន់តែច្រើនឡើង និងនាំឲ្យមានកំហឹងកើតឡើងក្នុងប្រទេសនោះ លោក ហ៊ុន សែន បានបង្ហាញជាថ្មីម្តងទៀតថា គាត់នឹងដោះស្រាយជាមួយអ្នកប្រឆាំងដោយប្រើកម្លាំង ជាជាងការប្រើការសន្ទនាពិភាក្សាគ្នា ហើយសុខចិត្តពន្យល់ដោះសារអំពីការស្លាប់របស់កុមារីអាយុ១៤ឆ្នាំ តាមរយៈការអះអាងអំពីការបង្កើតតំបន់អបគមន៍ ជាជាងបើកឲ្យមានការស៊ើបអង្កេតអំពីការសម្លាប់នោះ។

ជុំវិញការរួញខ្ចីចលំហាសម្រាប់សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ប្រភពផ្សព្វផ្សាយឯករាជ្យដូចជាវិទ្យុសំបុកឃ្មុំ និងអ្នកការពារសិទ្ធិមនុស្ស ដូចជានាយកវិទ្យុដែលហ៊ាននិយាយឥតសំចៃនេះគឺជាប្រភពដែលមានសារសំខាន់បំផុត។ ម.ស.ម.ក សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាទម្លាក់រាល់ការចោទប្រកាន់ទាំងអស់ទៅលើរូបលោក ម៉ម សូណង់ដូ និងដោះលែងគាត់ជាបន្ទាន់។ ប្រសិនបើលទ្ធិប្រជាធិបតេយ្យសេរី និងយុត្តិធម៌អាចនឹងក្លាយជាការពិតបានក្នុងប្រទេសកម្ពុជានោះ រដ្ឋាភិបាលមិនអាចបន្តរាំងស្ទះអ្នកប្រឆាំង និងទប់ស្កាត់អ្នករិះគន់ខ្លួននោះទេ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងប្រធាន ម.ស.ម.ក លោក អ៊ូ វីរៈ តាមទូរសព្ទ +855 (0)12 40 40 51 **ឬ អ៊ីម៉ែល** ouvirak@cchrcambodia.org **ឬ លោក រ៉ូប៊ឺត ហ្វីន តាមរយៈទូរសព្ទ** +855 (0) 78 80 99 60 **ឬ អ៊ីម៉ែល** robert.finch@cchrcambodia.org **។**